**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ ១៣៣៧០...ឧស.ឯ.ណ...[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ
## ក្នុងក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ ២០១៦

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសម្រាប់ឆ្នាំ២០១៦នេះចំនួន១៦៨ កន្លែង ដើម្បីបំពេញការងារនៅតាមទីស្តីការក្រសួង និងមន្ទីររាជធានី-ខេត្ត ដូចខាងក្រោម៖

**១- លក្ខខណ្ឌជ្រើសរើស ៖**

១.១. បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ជាតិខ្មែរ ហើយត្រូវមានអាយុស្របទៅតាមការកំណត់ដូចមានចែងខាងក្រោម៖

ក- ចំពោះបេក្ខជនជាសិស្ស និស្សិត ដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡងចូលក្របខណ្ឌប្រភេទ **ក** ត្រូវមានអាយុច្រើនបំផុតត្រឹម **៣០ឆ្នាំ** (ឬច្រើនបំផុតកើតក្នុងឆ្នាំ **១៩៨៦**) ។

ខ- ចំពោះបេក្ខជនជាសិស្ស និស្សិត ដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡងចូលក្របខណ្ឌប្រភេទ **ខ** ត្រូវមានអាយុច្រើនបំផុតត្រឹម **២៨ឆ្នាំ** (ឬច្រើនបំផុតកើតក្នុងឆ្នាំ **១៩៨៨**) ។

១.២. បេក្ខជនក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រទាបបំផុតសមមូលកម្រិតបរិញ្ញាប័ត្រ។ ចំពោះបេក្ខជនក្របខណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រទាបបំផុតសមមូលកម្រិតមធ្យមសិក្សាប័ត្រភាគទី ២+ ២ ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សា (បរិញ្ញាបត្ររង)។ បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ (Microsoft Word & Excel) ដែលមានវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ។

១.៣. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ។

១.៤. បេក្ខជនដែលដាក់ពាក្យសុំប្រឡងប្រជែងចូលបម្រើការងារនៅទីស្តីការក្រសួង ក៏ដូចជានៅតាមមន្ទីរឧស្សាកម្ម និងសិប្បកម្ម ត្រូវមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅរាជធានី-ខេត្តដែលខ្លួនបានចុះឈ្មោះប្រឡង។

១.៥. ការផ្តល់អាទិភាព និងលើកទឹកចិត្ត៖

១. ចំពោះបេក្ខជនជានារី ជនពិការ ដែលមានសមត្ថភាពសមស្របអាចបម្រើការងារបាន។

២. បេក្ខជននៅតំបន់ដាច់ស្រយាល ត្រូវបានលើកទឹកចិត្តសម្រាប់ការប្រឡង។

៣. បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា ដែលបានបម្រើការងារនៅតាមអង្គភាពនីមួយៗ ក្រោមឱវាទក្រសួង

៤. ចំពោះបេក្ខជន ដែលមានកម្រិតជំនាញបច្ចេកទេស ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ក្រសួង អាចនឹងទទួលបានការលើកទឹកចិត្តផងដែរ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263